ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តពោធិ៍សាត់

សាលក្រមរដ្ឋប្បវេណី

-លេខ: ១៥០ "ខ"

-ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣

-សំណុំរឿងរដ្ឋប្បវេណីលេខ: ៨៥

-ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តពោធិ៍សាត់

សញ្ញាណរឿងក្តី: **ប្តឹងសុំឱ្យសងប្រាក់**

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទីដប់ប្រាំបួន ខែកញ្ញា ឆ្នាំពីរពាន់ម្ភៃបី វេលាម៉ោង ពីរ និងសាមសិបនាទីរសៀល នៅសាលសវនាការដោយមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តពោធិ៍សាត់

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តពោធិ៍សាត់

ដើម្បីជំនុំជម្រះលើសំណុំរឿងរដ្ឋប្បវេណីលេខ: ៨៥ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ របស់សាលាដំបូងខេត្តពោធិ៍សាត់រវាង:

-ដើមចោទឈ្មោះ [redacted] សម្ផស្ស ភេទស្រី កើតឆ្នាំ១៩៨១ ជាតិខ្មែរ មានអាសយដ្ឋាន [redacted]

និងសហចុងចម្លើយ៖

-ឈ្មោះ [redacted] ថាវ៉ាវេត ភេទស្រី អាយុ៥៨ឆ្នាំ និងប្តីឈ្មោះ [redacted] ពន្លក កើតឆ្នាំ១៩៦១ ជាតិខ្មែរ អាសយដ្ឋាន [redacted] ។

-ឈ្មោះ [redacted] វ៉ាមិច ភេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរ អាសយដ្ឋាន [redacted] ។

-ឈ្មោះ [redacted] មុំ ភេទស្រី អាយុ៥៩ឆ្នាំ ជាតិខ្មែរ [redacted] ។

ដែលមានលោក [redacted] និងលោកស្រី [redacted] ជាអ្នកតំណាងដោយអាណត្តិ ។

### I. អង្គហេតុ និងចំណុចវិវាទ

**១. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ៖**

ប្តឹងសុំឱ្យសហកូនបំណុលឈ្មោះ [redacted] ថាវ៉ាវេត និង ប្តីឈ្មោះ [redacted] ពន្លក និង ឈ្មោះ [redacted] វ៉ាមិច និងឈ្មោះ [redacted] មុំ រួមគ្នាសង ៖

-ប្រាក់ដើមសរុបចំនួន ៧០,០០០ (ប្រាំពីរម៉ឺន) ដុល្លាអាមេរិក ។

-ការប្រាក់សរុបចំនួន ១១,៣៥០ (មួយម៉ឺនមួយពាន់បីរយហាសិប ) ដុល្លាអាមេរិក។

-សំណងជម្ងឺចិត្ត និងខាតពេលវេលា ចំនួន ១០,០០០ (មួយម៉ឺន) ដុល្លាអាមេរិក ។



Scanned with CamScanner

-ប្រាក់ពន្ធ និងប្រាក់ប្រដាប់ក្តី ។

-សុំឱ្យតុលាការអនុវត្តសាលក្រមជាបណ្តោះអាសន្ន ។

**២. ការពន្យល់ត្រួសៗអំពីរឿងក្តី**

នៅក្នុងរឿងក្តីនេះសហចុងចម្លើយឈ្មោះ [redacted] ថាវ៉ារ៉េត និងឈ្មោះ [redacted] ពន្លក និង ឈ្មោះ [redacted] វ៉ាមិច បានខ្ចីប្រាក់ពីដើមចោទឈ្មោះ [redacted] សម្ផស្ស ចំនួន USD ៧០,០០០ (ប្រាំពីរម៉ឺនដុល្លាអាមេរិក) តាមរយៈកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ២០២១ ដោយមានអត្រាការប្រាក់២,៥ភាគរយនៃចំនួនប្រាក់ដើមក្នុងមួយខែ ដោយមានឈ្មោះ [redacted] មុំ ជាអ្នកធានា ។ ក្រោយពីបានទទួលប្រាក់កម្ចីពីដើមចោទរួចហើយនោះសហចុងចម្លើយឈ្មោះ [redacted] វ៉ាមិច បានសងប្រាក់ទៅឱ្យដើមចោទបានចំនួន USD ៥,០០០ (ប្រាំពាន់ដុល្លាអាមេរិក) ប៉ុណ្ណោះ ហើយសហចុងចម្លើយក៏មិនបានបង់ការប្រាក់ទៅឱ្យដើមចោទតាមការសន្យានោះទេ ។ បើទោះបីជាដើមចោទបានទំនាក់ទំនងទៅខាងសហចុងចម្លើយឱ្យសងប្រាក់យ៉ាងណាក៏ដោយ ក៏សហចុងចម្លើយគេចវេសមិនព្រមចូលមកដោះស្រាយទៅអោយដើមចោទរហូតមកដល់បច្ចុប្បន្ន ។

**៣. អង្គហេតុដែលអះអាងដោយភាគីដើមចោទ**

-ដើមចោទឈ្មោះ [redacted] សម្ផស្ស បានធ្វើការអះអាងថា:នៅក្នុងរឿងនេះខ្លួនសុំរក្សាការទាមទារដូចមានក្នុងពាក្យបណ្តឹងចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ ដដែល ដោយប្តឹងសុំឱ្យសហចុងចម្លើយឈ្មោះ [redacted] ថាវ៉ារ៉េត និង ប្តីឈ្មោះ [redacted] ពន្លក ឈ្មោះ [redacted] វ៉ាមិច និងឈ្មោះ [redacted] មុំ ៖ ទី១ រួមគ្នាសងប្រាក់ដើមសរុបចំនួន៧០,០០០(ប្រាំពីរម៉ឺន) ដុល្លាអាមេរិក ទីពីរការប្រាក់សរុបចំនួន ១១,៣៥០ (មួយម៉ឺនមួយពាន់បីរយហាសិប) ដុល្លាអាមេរិក ទីបីសំណងជម្ងឺចិត្ត និងខាតពេលវេលា ចំនួន ១០,០០០ (មួយម៉ឺន) ដុល្លាអាមេរិក ទីបួន ប្រាក់ពន្ធ និងប្រាក់ប្រដាប់ក្តី និងទីប្រាំសុំឱ្យតុលាការអនុវត្តសាលក្រមជាបណ្តោះអាសន្ន ។ ដោយហេតុថា កាលពីថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០២១ សហចុងចម្លើយឈ្មោះ [redacted] ថាវ៉ារ៉េត និងប្តីឈ្មោះ [redacted] ពន្លក និងឈ្មោះ [redacted] វ៉ាមិច បានមកខ្ចីប្រាក់ពីខ្លួនចំនួន៧០,០០០(ប្រាំពីរម៉ឺន)ដុល្លាអាមេរិក តាមកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១ ដែលមានឈ្មោះ [redacted] មុំ ជាអ្នកធានាបំណុល។ ក្នុងការខ្ចីប្រាក់នេះខ្លួនបានប្រគល់ប្រាក់ឱ្យឈ្មោះ [redacted] ថាវ៉ារ៉េត និងប្តីឈ្មោះ [redacted] ពន្លក និងឈ្មោះ [redacted] វ៉ាមិច ជាបីដំណាក់កាល ដោយដំណាក់កាលទី ១ខ្លួនប្រគល់ចំនួន ៣៥,០០០ (បីម៉ឺនប្រាំពាន់) ដុល្លាអាមេរិក នៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០២១ ដំណាក់កាលទី២ ចំនួន ៥,០០០ (ប្រាំពាន់) ដុល្លាអាមេរិក នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ និងដំណាក់កាលទី៣ ចំនួន ៣០,០០០ (បីម៉ឺន) ដុល្លាអាមេរិក នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២១ ។ ក្រោយពីឈ្មោះ [redacted] ថាវ៉ារ៉េត និងប្តីឈ្មោះ [redacted] ពន្លក និងឈ្មោះ [redacted] វ៉ាមិច បានទទួលប្រាក់កម្ចីពីខ្លួនគ្រប់ចំនួនហើយ គឺឈ្មោះ [redacted] វ៉ាមិច បានសងមកខ្លួនចំនួន ៥,០០០ (ប្រាំពាន់) ដុល្លាអាមេរិក ប៉ុណ្ណោះដោយសព្វថ្ងៃនេះសហចុងចម្លើយនៅជំពាក់ប្រាក់ដើមចំនួន ៦៥,០០០ (ប្រាំមួយម៉ឺនប្រាំពាន់) ដុល្លាអាមេរិក គឺពួកគាត់មិនបានធ្វើការបង់ការប្រាក់ឱ្យមកខ្លួនតាមការសន្យានោះទេ ។ ក្រោយមកខ្លួនក៏បានទាមទារប្រាក់ដើម និងការប្រាក់ដែលឈ្មោះ [redacted] ថាវ៉ារ៉េត និងឈ្មោះ [redacted] ពន្លក និងឈ្មោះ [redacted] វ៉ាមិច បានជំពាក់ខ្លួន ប៉ុន្តែពួកគាត់តែងតែគេចវេសមិនព្រមចូលមកដោះស្រាយ ហើយខ្លួនបានទៅរកឈ្មោះ [redacted] មុំ ដែលជាអ្នកធានាផងដែរ ប៉ុន្តែឈ្មោះនេះក៏គេចវេសមិនព្រមដោះស្រាយជូនខ្លួនដូចគ្នារហូតមកដល់សព្វថ្ងៃនេះ។ ខ្លួននៅតែទាមទារឱ្យសហចុងចម្លើយទាំងបួននាក់រួមគ្នាសងប្រាក់មកខ្លួនតាមការទាមទារដដែល ។



Scanned with CamScanner

**៤. អង្គហេតុដែលអះអាងដោយភាគីចុងចម្លើយ**

-សហចុងចម្លើយឈ្មោះ [redacted] រ៉ាមិច បានធ្វើការអះអាងថា: ខ្លួន និងម្ដាយឈ្មោះ [redacted] ថារ៉ាវេត ទទួលស្គាល់ថាពិតជាបានជំពាក់ប្រាក់ដើមឈ្មោះ [redacted] សម្ផស្ស ចំនួនUSD ៧០,០០០(ប្រាំពីរម៉ឺនដុល្លាអាមេរិក) ប្រាកដមែន ប៉ុន្តែខ្លួនបានសងប្រាក់ដើមទៅដើមចោទចំនួន USD ៥,០០០ (ប្រាំពាន់ដុល្លាអាមេរិក) រួចហើយ នៅសល់ប្រាក់ដើមតែ USD ៦៥,០០០ (ប្រាំមួយម៉ឺនប្រាំពាន់ដុល្លាអាមេរិក) ដូចការអះអាងរបស់ដើមចោទ និងការប្រាក់សរុបចំនួន USD ១១,៣៥០(មួយម៉ឺនមួយពាន់បីរយហាសិបដុល្លាអាមេរិក) ប្រាកដមែន តែពេលនេះខ្លួនពុំទាន់មានលទ្ធភាពសងទៅអោយដើមចោទនៅឡើយទេ ។ ចំពោះចំណុចប្ដឹងទាមទារសំណងជម្ងឺចិត្ត និងខាតពេលវេលា ចំនួន USD ១០,០០០ (មួយម៉ឺន ដុល្លាអាមេរិក) ប្រាក់ពន្ធ និងប្រាក់ប្រដាប់ក្ដី និងចំណុចដែលដើមចោទសុំឱ្យតុលាការអនុវត្តសាលក្រមជាបណ្ដោះអាសន្នគឺខ្លួនសុំឱ្យតុលាការច្រានចោល ហើយចំពោះការប្ដឹងទាមទារទៅលើឈ្មោះ [redacted] ពន្លក និងឈ្មោះ [redacted] មុំ គឺសុំឱ្យតុលាការច្រានចោលដូចគ្នា ដោយហេតុថាខ្លួននិងម្ដាយជាអ្នកខ្ចីដូចនេះខ្លួននិងម្ដាយនឹងរួមគ្នាសងបំណុលឱ្យដើមចោទ។

-សហចុងចម្លើយឈ្មោះ [redacted] ថារ៉ាវេត បានធ្វើការអះអាងថា: ខ្លួនឯកភាពតាមសេចក្ដីថ្លែងការណ៍របស់កូនឈ្មោះ [redacted] រ៉ាមិច ទាំងស្រុង និងដោយសុំសងទៅដើមចោទនូវប្រាក់ដើមចំនួន USD៦៥,០០០ (ប្រាំមួយម៉ឺនប្រាំពាន់ដុល្លាអាមេរិក) និងការប្រាក់ចំនួនUSD ១១,៣៥០ (មួយម៉ឺនមួយពាន់បីរយហាសិបដុល្លាអាមេរិក)ប៉ុណ្ណោះ ។ ចំពោះការទាមទារផ្សេងៗរបស់ដើមចោទខ្លួនស្នើសុំឱ្យតុលាការច្រានចោលការទាមទាររបស់ដើមចោទ ។

-អ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] លីហួរ បានធ្វើសេចក្ដីថ្លែងការណ៍ថា: ពាក់ព័ន្ធនឹងការប្ដឹងទាមទារប្រាក់ពីកូនក្ដីខ្លួនឈ្មោះ [redacted] ពន្លក និងឈ្មោះ [redacted] មុំ គឺខ្លួនសុំឱ្យតុលាការច្រានចោលការទាមទាររបស់ដើមចោទ ដោយហេតុថាកូនក្ដីខ្លួនឈ្មោះ [redacted] រ៉ាមិច និងឈ្មោះ [redacted] ថារ៉ាវេត ជាអ្នកខ្ចី និងជាអ្នករ៉ាប់រងលើបំណុលនេះដោយមិនមានការពាក់ព័ន្ធនឹងកូនក្ដីខ្លួនឈ្មោះ [redacted] ពន្លក និងឈ្មោះ [redacted] មុំ នោះទេ ហើយការទាមទារសំណងជម្ងឺចិត្តនេះទៀតសោតគឺឃើញថាក្នុងក្រមរដ្ឋប្បវេណីពុំមានចែងអំពីសំណងជម្ងឺចិត្តនោះទេនិងការទាមទារសំណងជម្ងឺចិត្តរបស់ដើមចោទគឺមានទំហំលើសលប់ពេក និងពុំមានភស្តុតាងបញ្ជាក់អំពីការខូចខាតនោះទេ ។

-អ្នកតំណាងដោយអាណត្តិឱ្យសហចុងចម្លើយឈ្មោះ [redacted] ដាមន្នីវណ្ណ បានធ្វើសេចក្ដីថ្លែងការណ៍ថា: ខ្លួនឯកភាពចំពោះសេចក្ដីថ្លែងការណ៍របស់កូនក្ដីខ្លួនទាំងស្រុង ។

**៥.ចំណុចវិវាទ៖**

-ដើមចោទទាមទារឱ្យសហចុងចម្លើយរួមគ្នាសងប្រាក់ដើម និង ការប្រាក់គ្រប់ចំនួន តែសហចុងចម្លើយឈ្មោះ [redacted] រ៉ាមិច និងឈ្មោះ [redacted] ថារ៉ាវេត អះអាងថាខ្លួនពុំមានលទ្ធភាព ។

-ដើមចោទទាមទារឱ្យសហចុងចម្លើយសងជម្ងឺចិត្ត និង ប្រាក់ប្រដាប់ក្ដីតុលាការ និង សុំឱ្យតុលាការអនុវត្តបណ្ដោះអាសន្នតែសហចុងចម្លើយស្នើសុំឱ្យតុលាការច្រានចោលការទាមទាររបស់ដើមចោទ ។

**៦.ចំណុចគ្មានវិវាទ៖**

-ដើមចោទ និងចុងចម្លើយឯកភាពចំពោះការប្រាក់ចំនួន ១១,៣៥០ (មួយម៉ឺនមួយពាន់បីរយហាសិប) ដុល្លាអាមេរិក ។



Scanned with CamScanner

## II. ការពិនិត្យភស្តុតាង

**១.ភស្តុតាងជាឯកសាររបស់ដើមចោទ**

-ឯកសារទី១: ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ៨១ ពសរណ/២៣ ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០២៣ របស់សាលាដំបូងខេត្តពោធិ៍សាត់ (ថតចម្លង) ។

-ឯកសារទី២:ពាក្យសុំដីកាសម្រេចរក្សាការពារ ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ២០២៣ (ច្បាប់ដើម)

-ឯកសារទី៣:កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១ (ថតចម្លង) ។

-ឯកសារទី៤:កំណត់ហេតុប្រទល់មុខ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០២២ (ថតចម្លង) ។

-ឯកសារទី៥:កិច្ចសន្យា ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០២២ (ថតចម្លង) ។

-ឯកសារទី៦:ពត៏មានក្បាលដីសន្លឹកទី១ លេខក្បាលដី ១៥០៥០៦០៤-០២៧៣ (ថតចម្លង) ។

-ឯកសារទី៧:ពត៏មានក្បាលដីសន្លឹកទី២ លេខក្បាលដី ១៥០៥០៦០៤-០២៧៣ (ថតចម្លង) ។

-ឯកសារទី៨:វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៥០៥០៣០១-០៥៤៣ មានទីតាំងស្ថិតនៅភូមិពោធិ៍តាគួយ សង្កាត់លលកស ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ (ថតចម្លង) ។

-ឯកសារទី៩:កិច្ចសន្យាទិញលក់ដីឡូតិ៍ និងផ្ទះល្វែងថ្មីងក្រហម២ជាន់ ($E_0$ $E_1$) មានឡៅតឿ២បន្ទប់ជាន់$E_0$ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦ (ថតចម្លង) ។

**២.ភស្តុតាងជាឯកសាររបស់សហចុងចម្លើយ**

-គ្មាន។

## សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និង ការពិនិត្យភស្តុតាង តុលាការយល់ឃើញថា:

១.ពាក្យបណ្តឹងចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ របស់ឈ្មោះ [redacted] សម្ផស្ស មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ដូច្នេះសាលាដំបូងខេត្តពោធិ៍សាត់មានដែនសមត្ថកិច្ចដើម្បីវិនិច្ឆ័យស្របច្បាប់នូវពាក្យបណ្តឹង ហើយចេញសាលក្រមបានតាមមាត្រា ៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២.ដើមចោទ និងសហចុងចម្លើយ ពិតជាបានទំនាក់ទំនងគ្នាបង្កើតកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២២ ខែ តុលា ឆ្នាំ២០២១ និងកិច្ចសន្យា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ និងកិច្ចសន្យាចុះថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២១ ជាមួយគ្នាពិតប្រាកដមែន ។

៣.នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក៏ដូចជាក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ភាគីដើមចោទឈ្មោះ [redacted] សម្ផស្ស បានធ្វើការអះអាងថា ខ្លួនប្តឹងសុំឱ្យសហចុងចម្លើយឈ្មោះ [redacted] ថាវ៉ាវេត និង ប្តីឈ្មោះ [redacted] ពន្លក ឈ្មោះ [redacted] វ៉ាមិច និង ឈ្មោះ [redacted] មុំ ៖ ទី១ រួមគ្នាសងប្រាក់ដើមសរុបចំនួន ៧០,០០០ (ប្រាំពីរម៉ឺន)ដុល្លារអាមេរិក ទីពីរការប្រាក់សរុបចំនួន ១១,៣៥០ (មួយម៉ឺនមួយពាន់បីរយហាសិប) ដុល្លារអាមេរិក ទីបី សំណងជម្ងឺចិត្ត និងខាតពេលវេលាចំនួន ១០,០០០ (មួយម៉ឺន) ដុល្លារអាមេរិក ទីបួន ប្រាក់ពន្ធ និង ប្រាក់ប្រដាប់ក្តី និង ទីប្រាំសុំឱ្យតុលាការអនុវត្តសាលក្រមជាបណ្តោះអាសន្ន ដោយហេតុថា កាលពីថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០២១ សហចុងចម្លើយឈ្មោះ [redacted] ថាវ៉ាវេត និងប្តីឈ្មោះ [redacted] ពន្លក និងឈ្មោះ [redacted] វ៉ាមិច បានមកខ្ចីប្រាក់ពីខ្លួនចំនួន



Scanned with CamScanner

៧០,០០០(ប្រាំពីរម៉ឺន)ដុល្លាអាមេរិក តាមកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០២១ ដែលមានឈ្មោះ ស្រី[redacted]ជាអ្នកធានាបំណុល។ ក្នុងការខ្ចីប្រាក់នេះខ្លួនបានប្រគល់ប្រាក់ឱ្យឈ្មោះ[redacted]ថាភ៉ាវ៉េត និងប្ដីឈ្មោះ[redacted]ពន្លក និងឈ្មោះ [redacted]ភ៉ាមិច ជាបីដំណាក់កាល ដោយដំណាក់កាលទី១ខ្លួនប្រគល់ចំនួន៣៥,០០០(បីម៉ឺនប្រាំពាន់)ដុល្លាអាមេរិក នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១ ដំណាក់កាលទី២ ចំនួន៥,០០០ (ប្រាំពាន់) ដុល្លាអាមេរិក នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ និងដំណាក់កាលទី៣ ចំនួន ៣០,០០០(បីម៉ឺន) ដុល្លាអាមេរិក នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២១ ។ ក្រោយពីឈ្មោះ[redacted]ថាភ៉ាវ៉េត និងប្ដីឈ្មោះ[redacted]ពន្លក និងឈ្មោះ[redacted]ភ៉ាមិច បានទទួលប្រាក់កម្ចីពីខ្លួនគ្រប់ចំនួនហើយ គឺឈ្មោះ[redacted]ភ៉ាមិច បានសងមកខ្លួនចំនួន ៥,០០០(ប្រាំពាន់) ដុល្លាអាមេរិកប៉ុណ្ណោះ ដោយសព្វថ្ងៃនេះសហចុងចម្លើយនៅជំពាក់ប្រាក់ដើមចំនួន ៦៥,០០០ (ប្រាំមួយម៉ឺនប្រាំពាន់) ដុល្លាអាមេរិក គឺពួកគាត់មិនបានធ្វើការបង់ការប្រាក់ឱ្យមកខ្លួនតាមការសន្យានោះទេ ។ ក្រោយមកខ្លួនក៏បានទាមទារប្រាក់ដើម និងការប្រាក់ដែលឈ្មោះ [redacted] ថាភ៉ាវ៉េត និងឈ្មោះ [redacted] ពន្លក និងឈ្មោះ [redacted] ភ៉ាមិច បានជំពាក់ខ្លួន ប៉ុន្តែពួកគាត់តែងតែគេចវេសមិនព្រមចូលមកដោះស្រាយ ហើយខ្លួនបានទៅរកឈ្មោះ[redacted] មុំ ដែលជាអ្នកធានាផងដែរ ប៉ុន្តែឈ្មោះនេះក៏គេចវេសមិនព្រមដោះស្រាយជូនខ្លួនដូចគ្នារហូតមកដល់សព្វថ្ងៃនេះ ។ ខ្លួននៅតែទាមទារឱ្យសហចុងចម្លើយទាំងបួននាក់រួមគ្នាសងប្រាក់មកខ្លួនតាមការទាមទារដដែល ។ ហើយនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នេះដែរឈ្មោះ [redacted] ភ៉ាមិច បានធ្វើការអះអាងថា ខ្លួន និងម្ដាយឈ្មោះ [redacted] ថាភ៉ាវ៉េត ទទួលស្គាល់ថាខ្លួនពិតជាបានជំពាក់ប្រាក់ដើមឈ្មោះ [redacted] សម្ផស្ស ចំនួនUSD ៧០,០០០(ប្រាំពីរម៉ឺនដុល្លារអាមេរិក) ប្រាកដមែន ប៉ុន្តែខ្លួនបានសងប្រាក់ដើមទៅដើមចោទចំនួន USD ៥,០០០ (ប្រាំពាន់ដុល្លាអាមេរិក) រួចហើយ នៅសល់ប្រាក់ដើមតែ USD ៦៥,០០០ (ប្រាំមួយម៉ឺនប្រាំពាន់ដុល្លាអាមេរិក) ដូចការអះអាងរបស់ដើមចោទ និងការប្រាក់សរុបចំនួន USD ១១,៣៥០(មួយម៉ឺនមួយពាន់បីរយហាសិបដុល្លាអាមេរិក) ប្រាកដមែន តែពេលនេះខ្លួនពុំទាន់មានលទ្ធភាពសងទៅអោយដើមចោទនៅឡើយទេ ។ ចំពោះចំណុចប្ដឹងទាមទារសំណងជម្ងឺចិត្ត និង ខាតពេលវេលាចំនួន USD ១០,០០០ (មួយម៉ឺនដុល្លាអាមេរិក) ប្រាក់ពន្ធ និងប្រាក់ប្រដាប់ក្ដី និងចំណុចដែលដើមចោទសុំឱ្យតុលាការអនុវត្តសាលក្រមជាបណ្ដោះអាសន្នគឺខ្លួនសុំឱ្យតុលាការច្រានចោល ហើយចំពោះការប្ដឹងទាមទារទៅលើឈ្មោះ [redacted] ពន្លក និង ឈ្មោះ [redacted] មុំ គឺសុំឱ្យតុលាការច្រានចោលដូចគ្នា ដោយហេតុថាខ្លួន និងម្ដាយជាអ្នកខ្ចីដូចនេះខ្លួននិងម្ដាយនឹងរួមគ្នាសងបំណុលឱ្យដើមចោទ។ ជាងនេះទៅទៀត សហចុងចម្លើយឈ្មោះ [redacted] ថាភ៉ាវ៉េត បានធ្វើការអះអាងថា ខ្លួនឯកភាពតាមសេចក្ដីថ្លែងការណ៍របស់កូនឈ្មោះ[redacted]ភ៉ាមិច ទាំងស្រុង និងដោយសុំសងទៅដើមចោទនូវប្រាក់ដើមចំនួន USD៦៥,០០០ (ប្រាំមួយម៉ឺនប្រាំពាន់ដុល្លាអាមេរិក) និងការប្រាក់ចំនួនUSD ១១,៣៥០ (មួយម៉ឺនមួយពាន់បីរយហាសិបដុល្លាអាមេរិក)ប៉ុណ្ណោះ ។ ចំពោះការទាមទារផ្សេងៗរបស់ដើមចោទខ្លួនស្នើសុំឱ្យតុលាការច្រានចោលការទាមទាររបស់ដើមចោទ ។

៤.នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់អ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ[redacted]លីហួរ បានធ្វើសេចក្ដីថ្លែងការណ៍ថា ពាក់ព័ន្ធនឹងការប្ដឹងទាមទារប្រាក់ពីកូនក្ដីខ្លួនឈ្មោះ [redacted]ពន្លក និងឈ្មោះ [redacted]មុំ គឺខ្លួនសុំឱ្យតុលាការច្រានចោលការទាមទាររបស់ដើមចោទ ដោយហេតុថាកូនក្ដីខ្លួនឈ្មោះ[redacted]ភ៉ាមិច និង ឈ្មោះ [redacted] ថាភ៉ាវ៉េត ជាអ្នកខ្ចី និងជាអ្នករ៉ាប់រងលើបំណុលនេះដោយមិនមានការពាក់ព័ន្ធនឹងកូនក្ដីខ្លួនឈ្មោះ [redacted]ពន្លក និងឈ្មោះ [redacted] មុំ នោះទេ ហើយការទាមទារសំណងជម្ងឺចិត្តនេះទៀតសោតគឺឃើញថាក្នុងក្រមរដ្ឋប្បវេណីពុំមានចែងអំពីសំណងជម្ងឺចិត្តនោះទេនិងការទាមទារសំណងជម្ងឺចិត្តរបស់ដើមចោទគឺមានទំហំលើសលប់ពេក និងពុំមានភស្តុតាង



Scanned with CamScanner

បញ្ជាក់អំពីការខូចខាតនោះទេ ។ អ្នកតំណាងដោយអាណត្តិឱ្យសហចុងចម្លើយឈ្មោះ [redacted] ដាមនី្វណ្ណ បានធ្វើសេចក្តីថ្លែងការណ៍ថា: ខ្លួនឯកភាពចំពោះសេចក្តីថ្លែងការណ៍របស់កូនក្តីខ្លួនទាំងស្រុង ។

៥.តាមការអះអាងរបស់ដើមចោទឈ្មោះ [redacted] សម្ផស្ស ថាចាប់តាំងពីថ្ងៃខ្ចីប្រាក់មកសហចុងចម្លើយឈ្មោះ [redacted] ថាវ៉ាវ៉េត និងឈ្មោះ [redacted] វ៉ាមិច បានសងប្រាក់ដើមមកខ្លួនបានចំនួនUSD៥,០០០(ប្រាំពាន់ដុល្លារអាមេរិក) ប៉ុណ្ណោះបច្ចុប្បន្នគឺនៅជំពាក់ប្រាក់ដើមចំនួន USD៦៥,០០០ (ប្រាំ មួយម៉ឺនប្រាំពាន់ដុល្លារមេរិក) ព្រមទាំងការប្រាក់ចំនួនUSD ១១,៣៥០ (មួយម៉ឺនមួយពាន់បីរយហាសិបដុល្លាអាមេរិក) ។ សហចុងចម្លើយឈ្មោះ [redacted] ថាវ៉ាវ៉េត និងឈ្មោះ [redacted] វ៉ាមិច ក៏បានអះអាងនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ថាពួកខ្លួនទទួលស្គាល់ថាពិតជានៅជំពាក់ប្រាក់ដើមឈ្មោះ [redacted] សម្ផស្ស ចំនួន USD ៦៥,០០០(ប្រាំមួយម៉ឺនប្រាំពាន់ដុល្លារមេរិក) និងការប្រាក់ចំនួនUSD ១១,៣៥០ (មួយម៉ឺនមួយពាន់បីរយហាសិបដុល្លារអាមេរិក) ប្រាកដមែន ។ ដូច្នេះគប្បីតុលាការពិចារណានឹងសម្រេចទៅតាមការទាមទាររបស់ដើមចោទ ។

៦.ផ្អែកតាមការអះអាងរបស់ភាគីដើមចោទ និង តាមការអះអាងរបស់ភាគីសហចុងចម្លើយ ព្រមទាំងផ្អែកតាមការពិនិត្យភស្តុតាងនានា ដែលមានក្នុងសំណុំរឿងដែលជាកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១ ដែលដើមចោទដាក់ចូលមកតុលាការឃើញថា ពិតជាមានកម្ចីប្រាក់រវាងឈ្មោះ [redacted] សម្ផស្ស និង ប្តីឈ្មោះ [redacted] វណ្ណា ជាមួយឈ្មោះ [redacted] ថាវ៉ាវ៉េត ភេទស្រី ឈ្មោះ [redacted] វ៉ាមិច ភេទប្រុស ចំនួន USD ៧០,០០០ (ប្រាំពីរម៉ឺនដុល្លាអាមេរិក) ដោយមានអត្រាការប្រាក់ ២,៥ ភាគរយក្នុងមួយខែប្រាកដមែន និងយោងតាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១ នេះទៀតសោត ឃើញថាពិតជាមានឈ្មោះ [redacted] មុំ ភេទស្រី ជាអ្នកធានាបំណុលឱ្យអ្នកខ្ចីឈ្មោះ [redacted] ថាវ៉ាវ៉េត និងឈ្មោះ [redacted] វ៉ាមិច ប្រាកដមែន តុលាការយល់ឃើញថា កិច្ចសន្យានេះបានធ្វើឡើងដោយការព្រមព្រៀងពិតប្រាកដនិងដោយសេរីមិនមានការបង្ខិតបង្ខំឡើយ ដែលបង្ហាញឱ្យឃើញអំពីអត្ថិភាពនៃសិទ្ធិក្នុងការទាមទាររបស់ដើមចោទមានចំពោះសហចុងចម្លើយប្រាកដមែន ។ លើសពីនេះទៅទៀតតាមពាក្យបណ្តឹងរបស់ភាគីដើមចោទក៏បានប្តឹងសុំអោយតុលាការបង្គាប់អោយឈ្មោះ [redacted] ពន្លក រួមគ្នាសងប្រាក់មកអោយខ្លួនដែរ តែតាមការពិនិត្យកិច្ចសន្យារវាងគូភាគីតុលាការពិនិត្យឃើញថាឈ្មោះ [redacted] ពន្លក មិនមានពាក់ព័ន្ធ និងកិច្ចសន្យាខ្ចីប្រាក់នេះទេ ហេតុនេះគប្បីតុលាការច្រានចោលការទាមទាររបស់ភាគីដើមចោទត្រង់ចំណុចនេះ ។

៧.ដើមចោទបានបញ្ជាក់ថាចាប់តាំងពីភាគីសហចុងចម្លើយបានសងប្រាក់ខ្លួនជាបន្តបន្ទាប់មក ហើយសហចុងចម្លើយសព្វថ្ងៃនេះនៅជំពាក់ប្រាក់ដើមចំនួនUSD៦៥,០០០(ប្រាំមួយម៉ឺនប្រាំពាន់ដុល្លារមេរិក) ព្រមទាំងការប្រាក់ចំនួន USD១១,៣៥០ (មួយម៉ឺនមួយពាន់បីរយហាសិបដុល្លារអាមេរិក) មិនទាន់បានសងមកខ្លួននៅឡើយ ។ ចំណុចនេះអាចបញ្ជាក់អោយឃើញថាភាគីសហចុងចម្លើយមិនបានបំពេញនូវកាតព្វកិច្ច ដែលត្រូវសងប្រាក់អោយភាគីដើមចោទវិញនៅឡើយ ។ ដូចនេះគប្បីតុលាការពិចារណាតាមមាត្រា៥៩១នៃក្រមរដ្ឋប្បវេណី ។

៨.ដើមចោទទាមទារប្រាក់ការខាតបង់ពេលវេលាចំនួន USD១០,០០០(មួយម៉ឺនដុល្លាអាមេរិក)ពីសហចុងចម្លើយ។ ចំណុចនេះតុលាការយល់ឃើញថាកំហុសនេះកើតចេញពីទង្វើរបស់សហចុងចម្លើយដែលមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនហើយកំហុសនេះបង្កអោយមានការខាតបង់ដល់ភាគីដើមចោទ ។ ដូចនេះការទាមទាររបស់ដើមចោទមានលក្ខណៈសមស្របតាមមាត្រា៣៩៨ មាត្រា៤០០ និងមាត្រា៤០៤ នៃក្រមរដ្ឋប្បវេណី ប៉ុន្តែតុលាការយល់



Scanned with CamScanner

ឃើញថាការទាមទាររបស់ភាគីដើមចោទមានចំនួនច្រើនពេក ព្រោះប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់អ្នកចាញ់ក្ដី ។ ដូច្នេះគប្បីតុលាការពិចារណានិងសម្រេចទៅតាមភាពជាក់ស្ដែង ។

៩.ការទាមទាររបស់ដើមចោទអោយភាគីសហចុងចម្លើយជាអ្នកទទួលបន្ទុកប្រដាប់ក្ដី គប្បីតុលាការពិចារណាដោយផ្អែកតាមមាត្រា៦៤នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

១០.ដើមចោទប្ដឹងសុំឱ្យតុលាការប្រកាសថា សាលក្រមនេះមានអានុភាពអាចអនុវត្តជាបណ្ដោះអាសន្ននោះ តុលាការយល់ឃើញថាមានភាពសមស្របតាមមមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដោយហេតុថាដើមចោទបានប្ដឹងទាមទារប្រាក់ពីសហចុងចម្លើយ ដោយផ្អែកលើកិច្ចសន្យាខ្ចីប្រាក់ហើយសហចុងចម្លើយក៏បានទទួលស្គាល់នូវចំនួនប្រាក់ដើម និង ការប្រាក់ដែលនៅជំពាក់ដើមចោទដូចការអះអាងរបស់ដើមចោទដែរ ។ ហេតុនេះដើម្បីជាប្រយោជន៍របស់ភាគីដើមចោទ។ គប្បីតុលាការប្រកាសអោយសាលក្រមនេះអាចអនុវត្តជាបណ្ដោះអាសន្នលើប្រាក់ដើមចំនួនចំនួនUSD ៦៥,០០០ (ប្រាំមួយម៉ឺនប្រាំពាន់ដុល្លារអាមេរិក) ចំណុចក្រៅពីនេះគប្បីតុលាការច្រានចោល ។

១១.ប្រាក់ប្រដាប់ក្ដីត្រូវអនុវត្តតាមមាត្រា ៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្ដីសម្រេចបញ្ចប់

១-ឱ្យសហចុងចម្លើយឈ្មោះ [redacted] ថាវ៉ាវេត ឈ្មោះ [redacted] វ៉ាមិច និង ឈ្មោះ [redacted] មុំ រួមគ្នាសងប្រាក់ទៅដើមចោទឈ្មោះ [redacted] សម្ផស្ស ដូចខាងក្រោម៖

ក-ប្រាក់ដើមចំនួន USD **៦៥,០០០ (ប្រាំមួយម៉ឺនប្រាំពាន់ដុល្លារអាមេរិក)**។

ខ-ការប្រាក់ចំនួន USD **១១,៣៥០ (មួយម៉ឺនមួយពាន់បីរយហាសិបដុល្លារអាមេរិក)**។ ការទាមទារលើសពីនេះត្រូវច្រានចោល។

គ-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] ថាវ៉ាវេត ឈ្មោះ [redacted] វ៉ាមិច និងឈ្មោះ [redacted] មុំ រួមគ្នាសងការខាតបង់ពេលវេលាចំនួន ៤,០០០,០០០ (បួនលាន)រៀល ទៅដើមចោទឈ្មោះ [redacted] សម្ផស្ស ការទាមទារលើសពីនេះត្រូវច្រានចោល ។

២-សាលក្រមនេះអាចអនុវត្តជាបណ្ដោះអាសន្នត្រង់សេចក្ដីសម្រេចបញ្ចប់ចំណុចទី១ ចំនុច(ក) ចំណុចក្រៅពីនេះត្រូវច្រានចោល ។

៣-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគីសហចុងចម្លើយ ។

សាលក្រមនេះបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣។

គូភាគីមានសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងរយៈពេល០១(មួយ)ខែគិតចាប់ពីថ្ងៃបានទទួលសាលក្រមនេះ។

**ចៅក្រម**

ហត្ថលេខា និងត្រា: [redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ៥រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

ធ្វើនៅខេត្តពោធិ៍សាត់, ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]



Scanned with CamScanner